# ទំនុកដំកើង ៣៥

អធិស្ឋានដាក់បណ្ដាសា

១ ឱព្រះយេហូវ៉ាអើយ
សូមទ្រង់ការពារទូលបង្គំចំពោះពួកអ្នកដែលតតាំងនឹងទូលបង្គំ
សូមទ្រង់តស៊ូនឹងពួកអ្នកដែលតស៊ូនឹងទូលបង្គំផង
២ សូមចាប់យកទាំងខែលតូចធំ ហើយក្រោកឡើងជួយទូលបង្គំ
៣ សូមងាលំពែងរាំងផ្លូវពួកអ្នកដែលដេញតាមទូលបង្គំ
សូមមានព្រះបន្ទូលមកព្រលឹងទូលបង្គំថា ព្រះអង្គជាសេចក្ដីសង្គ្រោះនៃទូលបង្គំ
៤ សូមឲ្យអស់អ្នកដែលប៉ងអាក្រក់ដល់ព្រលឹងទូលបង្គំបានទៅជាមានសេចក្ដីខ្មាស ហើយអាប់យសទៅ
សូមឲ្យអស់អ្នកដែលគិតប្រទូសរ៉ាយដល់ទូលបង្គំបានត្រូវថយចេញដោយខ្មាសវិញ
៥ សូមឲ្យគេបានដូចជាចំបើងដែលខ្យល់ផាត់ទៅ ហើយឲ្យទេវតានៃព្រះយេហូវ៉ាដេញតាមគេផង
៦ សូមឲ្យផ្លូវគេបានងងឹត ហើយរអិល ព្រមទាំងមានទេវតានៃព្រះយេហូវ៉ាដេញតាមគេដែរ

ហេតុផល

៧ ដ្បិតគេបានលាក់អន្ទាក់នៅក្នុងរណ្ដៅ ដើម្បីចាប់ទូលបង្គំដោយឥតហេតុ
គេបានជីករណ្ដៅទាក់ព្រលឹងទូលបង្គំ ដោយឥតហេតុ

៨ សូមឲ្យសេចក្ដីហិនវិនាសលោមកលើគេដោយឥតដឹងខ្លួន
ហើយឲ្យអន្ទាក់ដែលគេបានលាក់នោះ ជាប់ខ្លួនគេវិញ
សូមឲ្យគេធ្លាក់ទៅជាប់អន្ទាក់នោះ ហើយវិនាសទៅផង

ការឆ្លើយតបចំពោះការសង្គ្រោះ

៩ នោះព្រលឹងទូលបង្គំនឹងមានសេចក្ដីអំណរក្នុងព្រះយេហូវ៉ា
ហើយនឹងមានសេចក្ដីរីករាយដោយសេចក្ដីសង្គ្រោះរបស់ទ្រង់
១០ អស់ទាំងឆ្អឹងនៃទូលបង្គំនឹងពោលថា
ឱព្រះយេហូវ៉ាអើយ តើមានអ្នកណាដូចទ្រង់
ដែលទ្រង់ជួយមនុស្សក្រីក្រឲ្យរួចពីអ្នកដែលខ្លាំងជាងខ្លួន
អើ ទាំងពួកក្រីក្រ និងមនុស្សកំសត់ឲ្យរួចពីអ្នករឹបជាន់ខ្លួន

ហេតុផល

១១ មានសាក្សីកោងលើកគ្នាឡើង
**គេ**ចោទសួរពីរឿងដែលទូលបង្គំមិនដឹង
១២ **គេ**ប្រព្រឹត្តការអាក្រក់ដល់ទូលបង្គំ ស្នងនឹងការល្អ
ដើម្បីឲ្យព្រលឹងទូលបង្គំត្រូវនៅតែឯង
១៣ តែឯទូលបង្គំ កាល**គេ**បានឈឺ នោះទូលបង្គំបានស្លៀកពាក់សំពត់ធ្មៃ
ទូលបង្គំបានសំដែងសេចក្ដីទុក្ខ ដោយតមអត់អាហារ
ហើយសេចក្ដីអធិស្ឋានរបស់ទូលបង្គំបានត្រឡប់ចូលមកក្នុងទ្រូងខ្លួនវិញ
១៤ ទូលបង្គំបានប្រព្រឹត្ត បែបដូចជា**អ្នកនោះ**ជាសំឡាញ់ ឬជាបងប្អូន
ទូលបង្គំបានឱនខ្លួនដោយសេចក្ដីសោក ដូចជាអ្នកដែលកាន់ទុក្ខចំពោះម្ដាយ
១៥ តែក្នុងគ្រាដែលទូលបង្គំកើតមានសេចក្ដីទំនាស់ចិត្ត
នោះ**គេ**បានអរសប្បាយវិញ ព្រមទាំងប្រជុំគ្នាផង
មនុស្សចង្រៃនោះ **គេ**ប្រជុំគ្នាទាស់នឹងទូលបង្គំ
តែទូលបង្គំមិនបានដឹងខ្លួនសោះ **គេ**បានហែកទូលបង្គំឥតឈប់ឈរ
១៦ **គេ**បានសំញែងធ្មេញដាក់ទូលបង្គំ ដូចជាពួកអ្នកមានពុត
ដែលប្រមាថ ក្នុងពេលលៀងលោមគ្នា

១៧ ឱព្រះអម្ចាស់អើយ តើទ្រង់នឹងព្រងើយចំពោះគេដល់កាលណាទៀត
សូមដោះព្រលឹងទូលបង្គំឲ្យរួចពីការបំផ្លាញរបស់គេ ហើយដួងជីវិតនៃទូលបង្គំឲ្យរួចពីសិង្ហ

១៨ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ នៅក្នុងពួកជំនុំធំ
ទូលបង្គំនឹងសរសើរដល់ទ្រង់ នៅកណ្ដាលមហាជន

១៩ សូមកុំឲ្យពួកខ្មាំងសត្រូវរបស់ទូលបង្គំមានសេចក្ដីអំណរ ដោយឈ្នះទូលបង្គំឡើយ
ក៏កុំឲ្យពួកអ្នកដែលស្អប់ទូលបង្គំ ដោយឥតហេតុ បានមិចភ្នែកដាក់គ្នាដែរ

ហេតុផល

២០ ដ្បិត**គេ**មិននិយាយដោយសេចក្ដីមេត្រីទេ
គឺ**គេ**គិតតែបង្កើតសេចក្ដីភូតភរ ចំពោះមនុស្សស្ងប់រំងាប់នៅក្នុងស្រុកវិញ
២១ អើ **គេ**ហាមាត់ធំទាស់នឹងទូលបង្គំ ដោយថា ន៏ ន៏ ភ្នែកយើងបានឃើញច្បាស់ហើយ

អធិស្ឋានដាក់បណ្ដាសា

២២ ឱព្រះយេហូវ៉ាអើយ ទ្រង់បានឃើញដែរ
**សូម**កុំនៅស្ងៀមឡើយ
ឱព្រះអម្ចាស់អើយ
**សូម**ទ្រង់កុំគង់ឆ្ងាយពីទូលបង្គំឲ្យសោះ
២៣ សូមទ្រង់រឭកឡើង ហើយតើនមកវិនិច្ឆ័យទូលបង្គំ ដោយយុត្តិធម៌
ឱព្រះដ៏ជាព្រះអម្ចាស់នៃទូលបង្គំអើយ
សូមវិនិច្ឆ័យរឿងក្តីនៃទូលបង្គំផង
២៤ ឱព្រះយេហូវ៉ាដ៏ជាព្រះនៃទូលបង្គំអើយ
សូមវិនិច្ឆ័យទូលបង្គំតាមសេចក្ដីសុចរិតរបស់ទ្រង់
សូមកុំឲ្យគេមានសេចក្ដីអំណរ ដោយឈ្នះទូលបង្គំឡើយ
២៥ កុំឲ្យគេគិតក្នុងចិត្តថា ន៍ សមដូចយើងប្រាថ្នាហើយ
កុំឲ្យគេថា យើងបានលេបវាបាត់ហើយ
២៦ ឯអស់អ្នកដែលអរសប្បាយ ដោយសេចក្ដីអន្តរាយរបស់ទូលបង្គំ
នោះ**សូម**ឲ្យគេទៅជាមានសេចក្ដីខ្មាស ហើយជ្រប់មុខចុះ
ឯអស់អ្នកដែលលើកគ្នាទាស់នឹងទូលបង្គំ
នោះ**សូម**ឲ្យគេហ៊ុមហ ដោយសេចក្ដីខ្មាស នឹងអាប់យសទៅ
២៧ តែអស់អ្នកណាដែលកាន់ខាងសេចក្ដីសុចរិតរបស់ទូលបង្គំ
**សូម**ឲ្យគេបានស្រែកហ៊ោឡើងដោយអំណរ ហើយសប្បាយវិញ
អើ **សូម**ឲ្យគេបានពោលជានិច្ចថា
**សូម**ឲ្យព្រះយេហូវ៉ាបានថ្កើងរុងរឿងឡើង ដែលទ្រង់សព្វព្រះហឫទ័យ
ចំពោះសេចក្ដីចំរើននៃអ្នកបំរើទ្រង់

២៨ យ៉ាងនោះ អណ្ដាតទូលបង្គំនឹងថ្លែងប្រាប់ ពីសេចក្ដីសុចរិតរបស់ទ្រង់
ហើយពីសេចក្ដីសរសើរនៃទ្រង់ជាដរាបរាល់ថ្ងៃ។